**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០១៣/០៨ របក.អគគ**

**របាយការណ៍ ស្ដីពី សកម្មភាពការងារប្រចាំខែ ឧសភា ឆ្នាំ ២០០៨**
**របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត**

ក្នុងខែ ឧសភា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្ដែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-ផ្ញើដីកាអមកំណត់ហេតុស្ដីពី កិច្ចប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨

-ផ្ញើដីកាអមកំណត់ហេតុស្ដីពី កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨

-ផ្ញើលិខិតទៅអង្គការ CCJAPIII ស្ដីពីការបញ្ចប់ការបង្កើតគេហទំព័រ (Website) ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨

-ផ្ញើលិខិតស្នើសុំការអនុញ្ញាតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ចុះហត្ថលេខាលើអនុសារណៈស្ដីពីការយោគយល់ គ្នារវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៃអង្គការ GTZ

-ផ្ញើលិខិតស្នើចាត់តាំងមន្ត្រីបង្គោល ២រូប ក្នុងលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ទទួលប្រាក់លាភការផ្អែកតាមលទ្ធផលការងារ ទៅអគ្គលេខាធិការគណៈកម្មាធិការ នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨

-ផ្ញើដីកាអមកំណត់បង្ហាញស្ដីពីតុលាការគំរូកម្ពុជា នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨

**ខ. ការងារកំណែទម្រង់**

-បានរៀបចំសិក្ខាសាលាស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិល លើការអនុវត្ត កម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅក្រុងព្រះសីហនុ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៨

-បានសហការជាមួយអគ្គស្នងការរង នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដើម្បីរៀបចំសន្និសីទជាតិស្តីពី ការរីកចម្រើនរបស់ប្រជាពលរដ្ឋ នៅថ្ងៃទី២៩-៣១ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨

-បានជួបពិភាក្សាជាមួយក្រុមការងារ DIHR លើដំណើរការជាបន្តនៃការរៀបចំសូចនាករតាមដានកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨

-ជួបពិភាក្សាជាមួយតំណាង UNDP រៀបចំផែនការការងារសម្រាប់បន្តគម្រោងប្រព័ន្ធទិន្នន័យសិទ្ធិមនុស្ស នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ និងទទួលសំភារៈបរិក្ខារមួយចំនួនពី UNDP សម្រាប់ដំណើរការគម្រោង នៅថ្ងៃទី១២ ខែឧសភា និងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨

-គម្រោងមូលដ្ឋានទិន្នន័យប្រភពធនធាននៃការបណ្តុះបណ្តាលសិទ្ធិមនុស្ស បានចាប់ផ្តើមអនុវត្តដោយមានជំនួយពី UNDP ដោយក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

-បានពិភាក្សាស្វែងរកការគាំទ្រពីគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការរបស់អង្គការ GTZ លើ ៣ គម្រោង មានគម្រោងការអង្កេតជាមូលដ្ឋានលើសមត្ថភាពច្បាប់ និងការតាក់តែងច្បាប់ គម្រោងការណែនាំប្រព័ន្ធ អំប៊ូស្មាន់ និងគម្រោងបោះពុម្ពផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្តិ

-បានចុះជួបពិភាក្សាជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជា CLEC, ADHOC Star Kampuchea, ILO, Open Forum និងក្រសួងយុត្តិធម៌ ដើម្បីសហការផ្តល់ព័ត៌មានដល់មូលដ្ឋានទិន្នន័យនៃការ បណ្តុះបណ្តាលសិទ្ធិមនុស្ស។

**គ. ផ្សេងៗ**

-ចូលរួមសន្និសីទស្តីពីការវិវត្តបច្ចុប្បន្នក្នុងវិស័យច្បាប់កម្ពុជា (កំណែទម្រង់ច្បាប់ និងតុលាការសម្រាប់ទំនើបកម្មច្បាប់នៅព្រះរាជាណាចក្រកម្ពុជា) នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ នៅព្រឹទ្ធសភា

-ចុះជួបអង្គការអ្នកផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សមួយចំនួន ដើម្បីសុំកិច្ចសហប្រតិបត្តិ-ការ ក្នុងការផ្តល់ និងបញ្ចូលព័ត៌មានក្នុងប្រព័ន្ធទិន្នន័យ

-បន្តរៀបចំសូចនាករតាមក្រុមគម្រោងទាំងអស់នៃអង្គភាពគ្រប់គ្រងគម្រោង

## ២-សន្និដ្ឋាន

ក្នុងខែ ឧសភា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានបន្តការងាររៀបចំសិក្ខាសាលាផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅក្រុងព្រះ-សីហនុ និងបន្តការងាររៀបចំប្រព័ន្ធសូចនាករសម្រាប់តាមដានការកែទម្រង់ច្បាប់និងតុលាការ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-គ្រោងរៀបចំពិធីចុះហត្ថលេខាលើអនុសារណៈស្តីពីការយោគយល់ គ្នារវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៃអង្គការ GTZ

-គ្រោងរៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ

-ចូលរួមរៀបចំបទអន្តរាគមន៍របស់ថ្នាក់ដឹកនាំ និងផ្តល់ឯកសារពាក់ព័ន្ធសម្រាប់សន្និសីទជាតិស្តីពីការរីកចម្រើនរបស់ប្រជាពលរដ្ឋ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊ួង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង